PRUDENTIAL
ព្រូដិនសល ធានារ៉ាប់រងអាយុជីវិត

បណ្ណាសន្យារ៉ាប់រង

PRUទ្រព្យ អេលីត

តារាងមាតិកា

១. និយមន័យ..... ២

២. កម្មវត្ថុនៃការធានា..... ៦

៣. វិសាលភាពនៃការធានា..... ៦

៤. អត្ថប្រយោជន៍នៃការធានា..... ៦

៥. ការបង់បុព្វលាភធានារ៉ាប់រង..... ៩

៦. ករណីមិនធានា..... ៩

៧. ទីតាំងភូមិសាស្ត្រនៃការធានា..... ១១

៨. លក្ខណៈសម្បត្តិអ្នកទទួលផល ឬ អ្នកទទួលសំណង..... ១១

៩. ការកែប្រែកិច្ចសន្យាធានារ៉ាប់រង..... ១២

១០. ការអស់សុពលភាពជាបណ្តោះអាសន្ន ឬការផ្អាកកិច្ចសន្យាធានារ៉ាប់រង ឬការបន្តសុពលភាព ឬការបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ..... ១៤

១១. ការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង..... ១៥

១២. ការលុបចោលកិច្ចសន្យាធានារ៉ាប់រង..... ១៦

១៣. នីតិវិធីនៃការទាមទារសំណង..... ១៦

១៤. ការរក្សាព័ត៌មានសម្ងាត់..... ១៨

១៥. ការផ្សះផ្សាវិវាទ..... ១៨

១៦. ដែនយុត្តាធិការ..... ១៨

១៧. ប្រការស្តីពីទណ្ឌកម្ម..... ១៩

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន ព្រូដិនសល
(ខេមបូឌា) ឡាយហ្វ៍ អ៊ិនស៊ួរែនស៍ ប.អ
PRUDENTIAL (CAMBODIA) LIFE ASSURANCE PLC
KINGDOM OF CAMBODIA

បណ្ណាសន្យារ៉ាប់រង

PRUទ្រព្យ អេលីត

នៅក្នុងឯកសារស្តីពី បណ្ណាសន្យារ៉ាប់រងនេះ ពាក្យ **"អ្នក"** ឬ **"របស់អ្នក"** សំដៅដល់ម្ចាស់បណ្ណាសន្យារ៉ាប់រង។ ពាក្យ **"យើង" "របស់យើង" "ក្រុមហ៊ុន" "របស់ក្រុមហ៊ុន"** ឬ **"ព្រូដិនសល"** សំដៅដល់ក្រុមហ៊ុន ព្រូដិនសល (ខេមបូឌា) ឡាយហ្វ៍ អឺស្សួរិនស៍ ម.ក។

១. និយមន័យ

១.១. គ្រោះថ្នាក់ចៃដន្យ សំដៅលើហេតុការណ៍ដែលមិនអាចដឹងមុន និងដោយចៃដន្យដែលជាមូលហេតុផ្ទាល់បណ្តាលឲ្យហេតុការណ៍ត្រូវបានធានាកើតឡើង ដោយសារកម្លាំងខាងក្រៅ និងដោយកត្តាផ្សេងៗដែលអាចមើលឃើញ ហើយដែលមិនបណ្តាលមកពីមូលហេតុ ដូចជា ជំងឺ ឬរោគារបស់អ្នកត្រូវបានធានារ៉ាប់រង។ ករណីធ្វើអត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាត ឬធ្វើឲ្យមានរបួសស្នាមលើខ្លួនឯង ដែលប្រព្រឹត្តដោយអ្នកត្រូវបានធានារ៉ាប់រង ទោះបីជាស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ នៅក្នុងអំឡុងពេលណាមួយដែលបណ្ណាសន្យារ៉ាប់រងនៅមានសុពលភាព នឹងមិនត្រូវបានចាត់ទុកថាជាគ្រោះថ្នាក់ចៃដន្យឡើយ។

១.២. កាលបរិច្ឆេទខួបប្រចាំឆ្នាំនៃបណ្ណាសន្យារ៉ាប់រង គឺជាកាលបរិច្ឆេទខួបប្រចាំឆ្នាំនៃកាលបរិច្ឆេទមានសុពលភាពនៃបណ្ណាសន្យារ៉ាប់រង។

១.៣. អត្ថប្រយោជន៍ចំណូលប្រចាំឆ្នាំ គឺជាអត្ថប្រយោជន៍ដែលត្រូវទទួលបានជាដំណាក់កាល ដែលម្ចាស់បណ្ណាសន្យារ៉ាប់រងមានសិទ្ធិទទួលបាន ប្រសិនបើបណ្ណាសន្យារ៉ាប់រងនោះនៅតែមានសុពលភាព និងគ្មានការបោះបង់កិច្ចសន្យាធានារ៉ាប់រង ឬការទាមទារសំណងករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ក្នុងអំឡុងពេលនៃការរាយតម្លៃអត្ថប្រយោជន៍ប្រាក់ចំណូលប្រចាំឆ្នាំ។

១.៤. អ្នកទទួលផល គឺជាបុគ្គលដែលបានកំណត់ដោយម្ចាស់បណ្ណាសន្យារ៉ាប់រង ដើម្បីទទួលអត្ថប្រយោជន៍ធានារ៉ាប់រង ស្របតាមឯកសារនៃបណ្ណាសន្យារ៉ាប់រងទាំងនេះ។

១.៥. អត្ថគាហកចុងក្រោយ សំដៅដល់រូបវន្តបុគ្គល ដែលត្រូវបានចាត់តាំងដោយម្ចាស់បណ្ណាសន្យារ៉ាប់រង ដើម្បីកាន់កាប់ ឬត្រួតត្រាចុងក្រោយបង្អស់ទៅលើនីតិបុគ្គល ក្នុងពេលដែលម្ចាស់បណ្ណាសន្យារ៉ាប់រងគឺជានីតិបុគ្គល។ អត្ថគាហកចុងក្រោយ ត្រូវបានកំណត់ថាជាបុគ្គលដែលកាន់កាប់ ឬគ្រប់គ្រងចុងក្រោយបង្អស់ដោយផ្ទាល់ ឬប្រយោលលើនីតិបុគ្គលដោយការកាន់កាប់ភាគហ៊ុនឬសិទ្ធិបោះឆ្នោត ឬក៏ជាបុគ្គលកាន់កាប់តាមរយៈមធ្យោបាយផ្សេងៗ នៅពេលដែលមិនមានបុគ្គលមានសិទ្ធិជាម្ចាស់កម្មសិទ្ធិណាម្នាក់ ឬពុំអាចកំណត់បុគ្គលដែលកំពុងកាន់កាប់សិទ្ធិជាអត្ថគាហកចុងក្រោយបាន។ នៅពេលពុំអាចកំណត់ថាបុគ្គលណាមួយជាអត្ថគាហកចុងក្រោយរបស់នីតិបុគ្គល បុគ្គល ដែលកាន់កាប់មុខតំណែងគ្រប់គ្រងជាន់ខ្ពស់នៅក្នុងនីតិបុគ្គលរបស់ម្ចាស់បណ្ណាសន្យារ៉ាប់រង នឹងត្រូវបានចាត់ទុកជាអត្ថគាហកចុងក្រោយ។

១.៦. កាលបរិច្ឆេទចុះបញ្ជីទាមទារសំណង គឺជាកាលបរិច្ឆេទដែលក្រុមហ៊ុនបានកត់ត្រា ចំពោះអ្នកទាមទារសំណងដែលបានបំពេញទាំងស្រុងនូវសំណើទាមទារសំណង និងបានដាក់រាល់ឯកសារទាមទារសំណងទាំងអស់ដែលក្រុមហ៊ុនបានតម្រូវសម្រាប់ធ្វើការទូទាត់ទឹកប្រាក់ធានារ៉ាប់រង យោងតាមឯកសារនៃបណ្ណសន្យារ៉ាប់រងដែលមានជាធរមាន។

១.៧. អាយុផុតកំណត់ គឺជាអាយុរបស់អ្នកត្រូវបានធានារ៉ាប់រង ដែលបណ្ណសន្យារ៉ាប់រងនៅបន្តផ្តល់ការការពារ រហូតដល់អាយុផុតកំណត់នោះ ក្រោយមកបណ្ណសន្យារ៉ាប់រងនេះនឹងត្រូវបញ្ចប់។ អាយុផុតកំណត់ ត្រូវបានជ្រើសរើសដោយម្ចាស់បណ្ណសន្យារ៉ាប់រង នៅកាលបរិច្ឆេទជាវបណ្ណសន្យារ៉ាប់រង ដែលមានជម្រើសអាយុផុតកំណត់ទាំងបីគឺ ៦៥ឆ្នាំ ៧០ឆ្នាំ និង ៧៥ឆ្នាំ នឹងត្រូវបានបញ្ជាក់ក្នុងវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិត។ អាយុផុតកំណត់ មិនអាចផ្លាស់ប្តូរបានឡើយបន្ទាប់ពីកាលបរិច្ឆេទចាប់ផ្តើមសុពលភាពនៃបណ្ណសន្យារ៉ាប់រង។

១.៨. រយៈពេលអនុគ្រោះ មានរយៈពេលហុកសិប (៦០) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដល់កាលកំណត់បង់បុព្វលាភធានារ៉ាប់រង គឺជាអំឡុងពេលមួយដែលម្ចាស់បណ្ណសន្យារ៉ាប់រងអាចបង់បុព្វលាភធានារ៉ាប់រងដែលពុំទាន់បានបង់។ ប្រសិនបើបុព្វលាភធានារ៉ាប់រងដែលពុំទាន់បានបង់នៅក្នុងកាលបរិច្ឆេទផុតកំណត់នៃរយៈពេលអនុគ្រោះនេះទេ នោះបណ្ណសន្យារ៉ាប់រងនឹងអស់សុពលភាពជាបណ្តោះអាសន្ន ដោយកាលបរិច្ឆេទអស់សុពលភាពជាបណ្តោះអាសន្ននេះ គឺត្រូវកំណត់យកកាលបរិច្ឆេទដល់កាលកំណត់បង់បុព្វលាភធានារ៉ាប់រង ដែលពុំទាន់បានបង់នោះ។

១.៩. តម្លៃនៃការបោះបង់កិច្ចសន្យាធានារ៉ាប់រង គឺជាចំនួនទឹកប្រាក់ដែលត្រូវបានធានាថានឹងទូទាត់ជូនទៅឱ្យម្ចាស់បណ្ណសន្យារ៉ាប់រង ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រងបញ្ចប់បណ្ណសន្យារ៉ាប់រងមុនកាលបរិច្ឆេទផុតកំណត់នៃបណ្ណសន្យារ៉ាប់រងនោះ ប៉ុន្តែលុះត្រាណាបណ្ណសន្យារ៉ាប់រងនោះនៅមានសុពលភាពពេញលេញ៖

(i). ក្នុងរយៈពេលម្ភៃបួន (២៤) ខែជាប់ៗគ្នា គិតចាប់ពីកាលបរិច្ឆេទមានសុពលភាពនៃបណ្ណសន្យារ៉ាប់រង និង

(ii). នៅកាលបរិច្ឆេទនៃការបញ្ចប់បណ្ណសន្យារ៉ាប់រងនោះ។

១.១០. ផលិតផលធានារ៉ាប់រង សំដៅដល់ផលិតផលធានារ៉ាប់រងអាយុជីវិត ដែលត្រូវបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិត។

១.១១. កាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រង គឺជាកាលបរិច្ឆេទដែលក្រុមហ៊ុនចេញវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិតជូនម្ចាស់បណ្ណសន្យារ៉ាប់រង និងត្រូវបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិត។

១.១២. ការកំណត់អត្ថប្រយោជន៍ធានារ៉ាប់រងសម្រាប់អនីតិជន គឺជាលក្ខខណ្ឌដែលកំណត់ថា អត្ថប្រយោជន៍ករណីមរណភាពឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ដែលត្រូវទូទាត់សម្រាប់អ្នកត្រូវបានធានារ៉ាប់រងជាអនីតិជន ត្រូវបានកម្រិតត្រឹមភាគរយជាក់លាក់នៃអត្ថប្រយោជន៍ដែលត្រូវអនុវត្ត ដោយផ្អែកលើអាយុរបស់អ្នកត្រូវបានធានារ៉ាប់រង នៅពេលព្រឹត្តិការណ៍ត្រូវបានធានាកើតឡើង។

១.១៣. ការអស់សុពលភាពជាបណ្តោះអាសន្ន ឬការផ្អាកកិច្ចសន្យាធានារ៉ាប់រង គឺជាការបាត់បង់ការធានារ៉ាប់រងជាបណ្តោះអាសន្ន ដោយសារបុព្វលាភធានារ៉ាប់រងដែលត្រូវបង់ មិនត្រូវបានបង់ទាន់ពេលវេលា។ ក្នុងករណីដែលបុព្វលាភធានារ៉ាប់រងនៅតែមិនត្រូវបានបង់បន្ទាប់ពីរយៈពេលអនុគ្រោះបានផុតកំណត់ នោះបណ្ណសន្យារ៉ាប់រងនឹងអស់សុពលភាពជា

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងរុជិនសេដ
(ខេមបូឌា) ផ្តាយល្ប៍ អ៊ិនស៊ួរែនស៍ ប.អ
PRUDENTIAL (CAMBODIA) LIFE ASSURANCE PLC
KINGDOM OF CAMBODIA

បណ្តោះអាសន្ន ហើយមិនមានអត្ថប្រយោជន៍ធានារ៉ាប់រងណាមួយត្រូវបានទូទាត់ឡើយ ក្នុងអំឡុងពេលដែលបណ្ណសន្យារ៉ាប់រងស្ថិតក្នុងស្ថានភាពអស់សុពលភាពជាបណ្តោះអាសន្ន។

១.១៤. កាលបរិច្ឆេទបណ្ណសន្យារ៉ាប់រងអស់សុពលភាពជាបណ្តោះអាសន្ន ជាកាលបរិច្ឆេទដែលបានកត់ត្រាដោយក្រុមហ៊ុនដែលបណ្ណសន្យារ៉ាប់រងផ្លាស់ប្តូរពី "មានសុពលភាព" ទៅជា "អស់សុពលភាពជាបណ្តោះអាសន្ន" ហើយពុំមានអត្ថប្រយោជន៍ធានារ៉ាប់រងនឹងត្រូវបានផ្តល់ជូននោះទេ។ លក្ខខណ្ឌពីការផ្លាស់ប្តូរបណ្ណសន្យារ៉ាប់រងពី "មានសុពលភាព" ទៅជា "អស់សុពលភាពជាបណ្តោះអាសន្ន" មានដូចបានពណ៌នានៅក្រោមចំណុច ១០។

១.១៥. អ្នកត្រូវបានធានារ៉ាប់រង សំដៅដល់បុគ្គលទាំងឡាយណាដែលរស់នៅក្នុងប្រទេសកម្ពុជា គិតចាប់ពីកាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រង និងត្រូវបានទទួលយកដោយក្រុមហ៊ុនសម្រាប់ការធានារ៉ាប់រង ស្របតាមឯកសារនៃបណ្ណសន្យារ៉ាប់រងដូចមានចែងនៅក្នុងឯកសារនេះ។

១.១៦. ការបង់បុព្វលាភធានារ៉ាប់រងក្នុងរយៈពេលកំណត់ សំដៅលើរចនាសម្ព័ន្ធនៃការបង់បុព្វលាភធានារ៉ាប់រង ដែលម្ចាស់បណ្ណសន្យារ៉ាប់រងបានបង់បុព្វលាភក្នុងរយៈពេលកំណត់មួយ ខណៈពេលដែលការការពារនៅតែបន្តមានសុពលភាពក្នុងរយៈពេលវែង ឬរហូតដល់រយៈពេលនៃបណ្ណសន្យារ៉ាប់រងបានបញ្ចប់។

១.១៧. អត្ថប្រយោជន៍ពេលដល់កាលកំណត់នៃបណ្ណសន្យារ៉ាប់រង គឺជាចំនួនទឹកប្រាក់ត្រូវបានធានាដែលត្រូវទូទាត់ជូនម្ចាស់បណ្ណសន្យារ៉ាប់រង នៅកាលបរិច្ឆេទផុតកំណត់នៃបណ្ណសន្យារ៉ាប់រង លុះត្រាណាតែបណ្ណសន្យារ៉ាប់រងមានសុពលភាពនៅកាលបរិច្ឆេទនោះ។

១.១៨. បណ្ណសន្យារ៉ាប់រង សំដៅទៅលើឯកសារចងភ្ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ដែលចេញដោយក្រុមហ៊ុនដោយមានកំណត់ពីខ្លឹមសារសំខាន់ៗ និងចែងពីខ និងលក្ខខណ្ឌលម្អិតដូចមានកំណត់នៅក្នុងបណ្ណសន្យារ៉ាប់រង ដែលបានព្រមព្រៀងរវាងក្រុមហ៊ុន និងម្ចាស់បណ្ណសន្យារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រង។

១.១៩. កាលបរិច្ឆេទមានសុពលភាពនៃបណ្ណសន្យារ៉ាប់រង គឺជាកាលបរិច្ឆេទដែលត្រូវបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិត ហើយគឺជាកាលបរិច្ឆេទដែលម្ចាស់បណ្ណសន្យារ៉ាប់រងបានបំពេញយ៉ាងត្រឹមត្រូវនូវទម្រង់បែបបទពាក្យស្នើសុំធានារ៉ាប់រង និងបង់បុព្វលាភធានារ៉ាប់រងគ្រប់ចំនួន ដោយយកកាលបរិច្ឆេទចុងក្រោយគេ យោងតាមឯកសារនៃបណ្ណសន្យារ៉ាប់រងដូចមានចែងក្នុងឯកសារនេះ ដរាបណាអ្នកត្រូវបានធានារ៉ាប់រងនៅតែមានជីវិតនៅកាលបរិច្ឆេទចេញវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិត។

១.២០. ម្ចាស់បណ្ណសន្យារ៉ាប់រង សំដៅដល់ស្ថាប័នណាមួយដែលបានចុះបញ្ជីតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងមានប្រតិបត្តិការនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឬបុគ្គលទាំងឡាយណាដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមានអាយុចាប់ពីដប់ប្រាំបី (១៨) ឆ្នាំឡើងទៅ ដែលមានសមត្ថភាពពេញលេញ និងជាអ្នកដែលបានបំពេញ និងចុះហត្ថលេខាលើទម្រង់បែបបទពាក្យស្នើសុំធានារ៉ាប់រង និងជាអ្នកបង់បុព្វលាភធានារ៉ាប់រង។

១.២១. រយៈពេលនៃបណ្ណសន្យារ៉ាប់រង គឺជារយៈពេលដែលការធានារ៉ាប់រងអាយុជីវិតមានសុពលភាព ហើយត្រូវបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិត។ រយៈពេលនៃបណ្ណសន្យារ៉ាប់រងមិនអាចផ្លាស់ប្តូរបានឡើយ បន្ទាប់ពីថ្ងៃ

ព្រះរាជាណាចក្រកម្ពុជា
ប្រមុំន ប្រជាសេរី
(ទេមបុជ) ខ្មាយ៉ាង អ៊ីសូរ៉ែនស៍ ប.អ
PRUDENTIAL (CAMBODIA) LIFE ASSURANCE PLC
KINGDOM OF CAMBODIA

ចាប់ផ្តើមបណ្ណសន្យារ៉ាប់រង។ រយៈពេលនៃបណ្ណសន្យារ៉ាប់រងមានភាពខុសគ្នា អាស្រ័យលើការជ្រើសរើសអាយុផុតកំណត់។ ឧទាហរណ៍ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងមានអាយុ សាមសិប (៣០)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទមានសុពលភាពនៃបណ្ណសន្យារ៉ាប់រង ហើយអាយុបញ្ចប់ដែលបានជ្រើសរើសគឺ ហុកសិបប្រាំ (៦៥)ឆ្នាំ នោះរយៈពេលនៃបណ្ណសន្យារ៉ាប់រងនឹងមានរយៈពេល សាមសិបប្រាំ (៣៥)ឆ្នាំ។

១.២២. ឆ្នាំបណ្ណសន្យារ៉ាប់រង គឺជារយៈពេលមួយឆ្នាំពេញគិតចាប់ពីកាលបរិច្ឆេទមានសុពលភាពនៃបណ្ណសន្យារ៉ាប់រងរហូតដល់ខួបប្រចាំឆ្នាំទីមួយនៃបណ្ណសន្យារ៉ាប់រង ឬខួបប្រចាំឆ្នាំណាមួយនៃបណ្ណសន្យារ៉ាប់រងនៃឆ្នាំបន្ទាប់ ដោយគិតចាប់ពីខួបប្រចាំឆ្នាំចុងក្រោយបង្អស់នៃបណ្ណសន្យារ៉ាប់រង។

១.២៣. បុព្វលាភធានារ៉ាប់រង គឺជាទឹកប្រាក់ដែលម្ចាស់បណ្ណសន្យារ៉ាប់រងយល់ព្រមបង់សម្រាប់ផលិតផលធានារ៉ាប់រង។ វិធីសាស្ត្រ និងរបៀបនៃការបង់បុព្វលាភធានារ៉ាប់រងនៃផលិតផលធានារ៉ាប់រង ត្រូវបានរៀបរាប់បញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង ឬលិខិតបញ្ជាក់ការផ្លាស់ប្តូរចុងក្រោយបំផុត ប្រសិនបើមាន។ ម្ចាស់បណ្ណសន្យារ៉ាប់រង ជាអ្នកទទួលខុសត្រូវលើការបង់ពន្ធលើបុព្វលាភធានារ៉ាប់រង និងពន្ធណាមួយដែលអនុវត្តចំពោះបណ្ណសន្យារ៉ាប់រងដែលបានចេញជូន ប្រសិនបើមាន។

១.២៤. ចំនួនទឹកប្រាក់ត្រូវបានធានារ៉ាប់រង គឺជាចំនួនទឹកប្រាក់ដែលម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវការសម្រាប់ជាការធានារ៉ាប់រងសម្រាប់ផលិតផលធានារ៉ាប់រង ដែលនឹងទទួលបាននៅពេលមានព្រឹត្តិការណ៍ស្ថិតក្នុងការធានាណាមួយកើតឡើងយោងតាមឯកសារនៃបណ្ណសន្យារ៉ាប់រងដូចមានចែងក្នុងឯកសារនេះ។ ចំនួនទឹកប្រាក់ត្រូវបានធានារ៉ាប់រង នឹងត្រូវបានកំណត់ដោយម្ចាស់បណ្ណសន្យារ៉ាប់រងនៅពេលជាវបណ្ណសន្យារ៉ាប់រង។

១.២៥. ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ គឺជាស្ថានភាពមួយដែលអសមត្ថភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ហើយមានទម្រង់ដូចខាងក្រោម៖

(i) ការបាត់បង់ទាំងស្រុង ឬ ការមើលមិនឃើញ និងមិនអាចជាសះស្បើយជារៀងរហូតនៃភ្នែកទាំងពីរ ឬ

(ii) ការបាត់បង់ទាំងស្រុង និងមិនអាចជាសះស្បើយជារៀងរហូតនៃមុខងារប្រើប្រាស់របស់ដៃ/ជើងទាំងពីរ នៅត្រង់កដៃ/កជើង ឬចាប់ពីផ្នែកខាងលើនៃកដៃ/កជើង ឬ

(iii) ការបាត់បង់ទាំងស្រុង ឬការមើលមិនឃើញ និងមិនអាចជាសះស្បើយជារៀងរហូតនៃភ្នែកម្ខាង និងការបាត់បង់ទាំងស្រុង និងមិនអាចជាសះស្បើយជារៀងរហូតនៃមុខងារប្រើប្រាស់របស់ដៃ/ជើងម្ខាង នៅត្រង់កដៃ/កជើង ឬចាប់ពីផ្នែកខាងលើនៃកដៃ/កជើង។

នៅក្នុងករណីដែលមានការបាត់បង់ទាំងស្រុង និងមិនអាចជាសះស្បើយជារៀងរហូតនៃមុខងារប្រើប្រាស់នូវដៃ/ជើងម្ខាង ឬទាំងពីរនៅត្រឹមកដៃ/កជើង ឬចាប់ពីផ្នែកខាងលើនៃកដៃ/កជើង ការវិភាគកោសល្យវិច្ច័យអំពីអាការៈនេះត្រូវធ្វើឡើងដោយមន្ទីរពេទ្យដែលមានចុះបញ្ជីត្រឹមត្រូវ នៅថ្នាក់ខេត្ត ឬរាជធានី មិនឲ្យតិចជាងរយៈពេលប្រាំមួយ (៦) ខែ ហើយក៏មិនឲ្យលើសពីរយៈពេលប្រាំបួន (៩) ខែ គិតចាប់តាំងពីថ្ងៃដែលមានហេតុការណ៍ត្រូវបានធានាកើតឡើង ឬក៏គិតចាប់ពីថ្ងៃដែលការវិភាគកោសល្យវិច្ច័យអំពីអាការៈនេះ ត្រូវបានបញ្ជាក់ត្រឹមត្រូវ។

នៅក្នុងករណីដែលមានការបាត់បង់ទាំងស្រុង និងមិនអាចជាសះស្បើយជារៀងរហូត ការវិភាគកោសល្យវិច្ឆ័យអំពីអាការៈនេះត្រូវធ្វើឡើងដោយមន្ទីរពេទ្យដែលមានចុះបញ្ជីត្រឹមត្រូវ នៅថ្នាក់ខេត្ត ឬរាជធានី។ ការវិភាគកោសល្យវិច្ឆ័យអំពីអាការៈនេះ អាចធ្វើឡើងនៅពេលណាមួយក៏បាននៅក្នុងរយៈពេលនៃបណ្ណាសន្យាវ៉ាប់រង ឬនៅក្នុងរយៈពេលដែលបណ្ណាសន្យាវ៉ាប់រងនៅមានសុពលភាពនៅឡើយ។

១.២៦. បណ្ណាសន្យាវ៉ាប់រងនៅមានសុពលភាព មានន័យថាបណ្ណាសន្យាវ៉ាប់រងដែល (១) មិនទាន់អស់សុពលភាពជាបណ្តោះអាសន្ន (២) មិនទាន់ត្រូវបានបញ្ចប់ដោយខ និងលក្ខខណ្ឌនៅក្រោមបណ្ណាសន្យាវ៉ាប់រងនេះ។

២. កម្មវត្ថុនៃការធានា

ផលិតផលធានារ៉ាប់រងនេះ ផ្តល់ជូនការធានារ៉ាប់រងទៅលើអាយុជីវិត ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងបានទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ដូចដែលបានចែងក្នុងចំណុចទី ៤.១ និង ៤.២ និងផ្តល់អត្ថប្រយោជន៍ចំណូលប្រចាំឆ្នាំ និងអត្ថប្រយោជន៍ពេលដល់កាលកំណត់នៃបណ្ណាសន្យាវ៉ាប់រង ដូចដែលមានចែងក្នុងចំណុច ៤.៣ និង ៤.៤។

៣. វិសាលភាពនៃការធានា

ផលិតផលធានារ៉ាប់រងនេះ ផ្តល់ជូនការធានារ៉ាប់រងទៅលើអាយុជីវិត ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងបានទទួលមរណភាព ឬ ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ដែលបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ ឬមិនបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ ដូចដែលបានចែងក្នុងចំណុចទី៤.១ និង៤.២ និងផ្តល់អត្ថប្រយោជន៍ចំណូលប្រចាំឆ្នាំ និងអត្ថប្រយោជន៍ពេលដល់កាលកំណត់នៃបណ្ណាសន្យាវ៉ាប់រង ដូចដែលមានចែងក្នុងចំណុច ៤.៣ និង៤.៤។

៤. អត្ថប្រយោជន៍នៃការធានា

៤.១ អត្ថប្រយោជន៍ករណីមរណភាព ឬករណីពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដែលមិនបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ

ក្នុងករណីដែលអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ដែលមិនបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ ក្រុមហ៊ុនត្រូវធ្វើការទូទាត់ជូនអ្នកទទួលផលនូវ៖

(i) អត្ថប្រយោជន៍ករណីមរណភាព ឬករណីពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ដែលមិនបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ ដូចមានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិត ឬលិខិតបញ្ជាក់ការផ្លាស់ប្តូរចុងក្រោយបំផុត (ប្រសិនបើមាន) និងដកមកវិញនូវ

(ii) ចំនួនទឹកប្រាក់ណាមួយដែលនៅជំពាក់ក្រុមហ៊ុន (ប្រសិនបើមាន)។

អត្ថប្រយោជន៍ករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ដែលមិនបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ ដូចដែលបានចែងក្នុងចំណុច ៤.១ នេះ គឺស្មើនឹង មួយរយភាគរយ (១០០%) នៃចំនួនទឹកប្រាក់ត្រូវបានធានារ៉ាប់រង ក្នុងឆ្នាំទី១ និងបន្តកើនឡើងជាលំដាប់ទៅតាមចំនួនឆ្នាំនៃបណ្ណាសន្យាវ៉ាប់រង រហូតដល់ ប្រាំពីររយភាគរយ (៧០០%) នៃចំនួនទឹក

ប្រាក់ត្រូវបានធានារ៉ាប់រង ចាប់ពីឆ្នាំទី ៧ តទៅដូចមានចែងនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិត ដែលនេះនឹងផ្អែកលើការកំណត់អត្ថប្រយោជន៍សម្រាប់អនីតិជន ដូចដែលបានចែងក្នុងចំណុច ៤.៣។

បណ្ណាសន្យារ៉ាប់រងនឹងត្រូវបញ្ចប់ បន្ទាប់ពីការទូទាត់អត្ថប្រយោជន៍នេះ។

៤.២ អត្ថប្រយោជន៍ករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដោយសារគ្រោះថ្នាក់ចៃដន្យ

ក្នុងករណីដែលអ្នកត្រូវបានបានធានារ៉ាប់រងទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ដែលបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ ក្រុមហ៊ុននឹងបង់ជូនអ្នកទទួលផល៖

(i) អត្ថប្រយោជន៍ករណីមរណភាព ឬករណីពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដែលបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ ដូចមានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិត ឬលិខិតបញ្ជាក់ការផ្លាស់ប្តូរចុងក្រោយបំផុត (ប្រសិនបើមាន) និងដកមកវិញនូវ

(ii) ចំនួនទឹកប្រាក់ណាមួយដែលនៅជំពាក់ក្រុមហ៊ុន (ប្រសិនបើមាន)។

អត្ថប្រយោជន៍ករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដែលបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ ដូចដែលបានចែងក្នុងចំណុចទី ៤.២ គឺស្មើនឹង បី (៣) ដង នៃអត្ថប្រយោជន៍ករណីមរណភាព ឬករណីពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដែលមិនបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ ដូចដែលបានចែងក្នុងចំណុចទី ៤.១ និងដូចមានចែងនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិត ដែលនេះនឹងផ្អែកលើការកំណត់អត្ថប្រយោជន៍សម្រាប់អនីតិជន ដូចដែលបានចែងក្នុងចំណុច ៤.៣។

បណ្ណាសន្យារ៉ាប់រងនឹងត្រូវបញ្ចប់ បន្ទាប់ពីការទូទាត់អត្ថប្រយោជន៍នេះ។

៤.៣ អត្ថប្រយោជន៍សម្រាប់អនីតិជន

ទោះបីជាមានចែងផ្សេងពីនេះនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិត ក្នុងករណីដែលហេតុការណ៍ដែលត្រូវបានធានាកើតឡើងចំពោះអ្នកត្រូវបានធានារ៉ាប់រង មុនពេលដែលអ្នកត្រូវបានធានារ៉ាប់រងមានអាយុបួន (៤) ឆ្នាំ (អាយុនៅថ្ងៃខួបកំណើតចុងក្រោយ) នោះគ្រប់អត្ថប្រយោជន៍ធានារ៉ាប់រងទាំងអស់នឹងត្រូវបានទូទាត់ជូនតាមលក្ខខណ្ឌដូចខាងក្រោម៖

អាយុរបស់អ្នកត្រូវបានធានារ៉ាប់រង នៅពេលដែលហេតុការណ៍ដែលត្រូវបានធានា កើតឡើង (នៅថ្ងៃខួបកំណើតចុងក្រោយ)	អត្ថប្រយោជន៍ធានារ៉ាប់រងដែលត្រូវទូទាត់ ជាភាគរយនៃអត្ថប្រយោជន៍ធានារ៉ាប់រងដែលមានចែងក្នុងវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិត
ក្រោម ២ ឆ្នាំ	៤០%
២ ឆ្នាំ – ក្រោម ៣ ឆ្នាំ	៦០%
៣ ឆ្នាំ – ក្រោម ៤ ឆ្នាំ	៨០%
៤ ឆ្នាំឡើងទៅ	១០០%

បណ្ណាសន្យារ៉ាប់រងត្រូវបានបញ្ចប់ បន្ទាប់ពីការទូទាត់អត្ថប្រយោជន៍នេះ។

៤.៤ អត្ថប្រយោជន៍ចំណូលប្រចាំឆ្នាំ

អត្ថប្រយោជន៍ចំណូលប្រចាំឆ្នាំ ដែលស្មើនឹង ប្រាំភាគរយ (៥%) នៃចំនួនទឹកប្រាក់ត្រូវបានធានារ៉ាប់រង នឹងត្រូវផ្តល់ជូននៅដើមគ្រានៃខួបនៃបណ្ណសន្យារ៉ាប់រង រាប់ចាប់ពីឆ្នាំទី២នៃបណ្ណសន្យារ៉ាប់រងរហូតដល់ខួបចុងក្រោយបង្អស់នៃបណ្ណសន្យារ៉ាប់រង មុនពេលរយៈពេលនៃបណ្ណសន្យារ៉ាប់រងបានបញ្ចប់ ក្នុងលក្ខខណ្ឌ ដូចខាងក្រោម៖

(i) បណ្ណសន្យារ៉ាប់រង នៅតែមានសុពលភាព ក្នុងអំឡុងពេលនៃការវាយតម្លៃអត្ថប្រយោជន៍ចំណូលប្រចាំឆ្នាំ និង

(ii) គ្មានការបោះបង់បណ្ណសន្យាធានារ៉ាប់រង ឬគ្មានការទាមទារសំណងករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ក្នុងអំឡុងពេលនៃការវាយតម្លៃអត្ថប្រយោជន៍ចំណូលប្រចាំឆ្នាំ។

ក្រុមហ៊ុន នឹងមិនទូទាត់អត្ថប្រយោជន៍ចំណូលប្រចាំឆ្នាំឡើយ នៅពេលដែលបណ្ណសន្យារ៉ាប់រងអស់សុពលភាពជាបណ្តោះអាសន្ន។ អត្ថប្រយោជន៍ចំណូលប្រចាំឆ្នាំ នឹងត្រូវបន្តផ្តល់ជូនវិញ បន្ទាប់ពីបណ្ណសន្យារ៉ាប់រងបានបន្តសុពលភាពឡើងវិញ ដែលនឹងត្រូវទូទាត់ចាប់ពីខួបបន្ទាប់នៃបណ្ណសន្យារ៉ាប់រង ក្រោយកាលបរិច្ឆេទមានសុពលភាពឡើងវិញនៃបណ្ណសន្យារ៉ាប់រងដោយអនុលោមតាមខ និងលក្ខខណ្ឌនានានៃបណ្ណសន្យារ៉ាប់រងនេះ។

ម្ចាស់បណ្ណសន្យារ៉ាប់រងនឹងទទួលបានអត្ថប្រយោជន៍ចំណូលប្រចាំឆ្នាំតាមរយៈ៖

ក. ផ្ទេរប្រាក់តាមគណនីធនាគារ៖

អត្ថប្រយោជន៍ចំណូលប្រចាំឆ្នាំ នឹងត្រូវផ្ទេរទៅកាន់គណនីធនាគារដែលបានផ្តល់ជូន ដោយម្ចាស់បណ្ណសន្យារ៉ាប់រងនៅពេលដាក់ពាក្យស្នើសុំបណ្ណសន្យារ៉ាប់រង។

ខ. ការទូទាត់កាត់កងជាមួយបុព្វលាភធានារ៉ាប់រងដល់កាលកំណត់បន្ទាប់ដែលត្រូវបង់៖

ម្ចាស់បណ្ណសន្យារ៉ាប់រង មានជម្រើសក្នុងការទូទាត់កាត់កងអត្ថប្រយោជន៍ចំណូលប្រចាំឆ្នាំ ជាមួយនឹងបុព្វលាភធានារ៉ាប់រងសម្រាប់ការបន្តសុពលភាពលើកក្រោយ។ ជម្រើសនេះត្រូវតែជ្រើសរើសនៅពេលដាក់ពាក្យស្នើសុំបណ្ណសន្យារ៉ាប់រង ហើយអាចផ្លាស់ប្តូរបានក្នុងអំឡុងរយៈពេលបង់បុព្វលាភធានារ៉ាប់រង ដោយធ្វើការស្នើសុំពីម្ចាស់បណ្ណសន្យារ៉ាប់រង។

ក្នុងជម្រើសនេះ ក្រុមហ៊ុននឹងមិនធ្វើការទូទាត់កាត់កងអត្ថប្រយោជន៍ចំណូលប្រចាំឆ្នាំឡើយ ប្រសិនបើបុព្វលាភធានារ៉ាប់រងសម្រាប់ការបន្តសុពលភាពដែលដល់កាលកំណត់មិនទាន់ត្រូវបានបង់។ អត្ថប្រយោជន៍ចំណូលប្រចាំឆ្នាំនឹងត្រូវរក្សាទុក ហើយនឹងទូទាត់កាត់កងឡើងវិញបាន លុះត្រាតែបុព្វលាភសម្រាប់ការបន្តសុពលភាពនោះ ត្រូវបានបង់នៅពេលក្រោយ ឬត្រូវទូទាត់ជូនម្ចាស់បណ្ណសន្យារ៉ាប់រង រួមជាមួយនឹងតម្លៃនៃការបោះបង់កិច្ចសន្យាធានារ៉ាប់រង ក្នុងករណីដែលមានការបោះបង់កិច្ចសន្យាធានារ៉ាប់រង ឬការបញ្ចប់បណ្ណសន្យាធានារ៉ាប់រងកើតឡើង ឬទូទាត់ជាមួយនឹងអត្ថប្រយោជន៍ធានារ៉ាប់រង ក្រោមប្រការ ៤.១ ឬ ៤.២។

បន្ទាប់ពីបុព្វលាភធានារ៉ាប់រងទាំងអស់ ត្រូវបានទូទាត់រួច យើងនឹងធ្វើការផ្ទេរអត្ថប្រយោជន៍ចំណូលប្រចាំឆ្នាំ ទៅកាន់គណនីធនាគារដែលបានផ្តល់ជូន ដោយម្ចាស់បណ្ណសន្យារ៉ាប់រងនៅពេលដាក់ពាក្យស្នើសុំបណ្ណសន្យារ៉ាប់រង។

៤.៥ អត្ថប្រយោជន៍ពេលដល់កាលកំណត់នៃបណ្ណសន្យារ៉ាប់រង

ក្នុងករណីដែលបណ្ណសន្យារ៉ាប់រង នៅមានសុពលភាពរហូតដល់កាលបរិច្ឆេទផុតកំណត់នៃបណ្ណសន្យារ៉ាប់រង នោះម្ចាស់បណ្ណសន្យារ៉ាប់រងនឹងត្រូវទទួលបានអត្ថប្រយោជន៍ពេលដល់កាលកំណត់នៃបណ្ណសន្យារ៉ាប់រង ដែលមាននៅក្រោមបណ្ណសន្យារ៉ាប់រងនេះ ដោយដកយកមកវិញនូវ ចំនួនទឹកប្រាក់ណាមួយដែលនៅជំពាក់ក្រុមហ៊ុន (ប្រសិនបើមាន)។

អត្ថប្រយោជន៍ពេលដល់កាលកំណត់នៃបណ្ណសន្យារ៉ាប់រង គឺស្មើនឹងតម្លៃ ៦៥% ឬ៧០% ឬ៧៥% នៃចំនួនទឹកប្រាក់ត្រូវបានធានារ៉ាប់រង អាស្រ័យលើអាយុផុតកំណត់ ដែលបានជ្រើសរើសនៅកាលបរិច្ឆេទមានសុពលភាពនៃបណ្ណសន្យារ៉ាប់រង និងបានចែងនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិត។

អាយុផុតកំណត់	**អត្ថប្រយោជន៍ពេលដល់កាលកំណត់នៃបណ្ណសន្យារ៉ាប់រង % នៃចំនួនទឹកប្រាក់ត្រូវបានធានារ៉ាប់រង**
៦៥	៦៥0%
៧0	៧00%
៧៥	៧៥0%

បណ្ណសន្យារ៉ាប់រង នឹងត្រូវបញ្ចប់បន្ទាប់ពីត្ថប្រយោជន៍ពេលដល់កាលកំណត់នៃបណ្ណសន្យារ៉ាប់រងនេះ ត្រូវបានទូទាត់ជូន។

៥. ការបង់បុព្វលាភធានារ៉ាប់រង

ជម្រើសនៃការបង់បុព្វលាភ គឺការបង់បុព្វលាភធានារ៉ាប់រងក្នុងរយៈពេលកំណត់។ បុព្វលាភធានារ៉ាប់រង អាចបង់ទៅកាន់គណនីធនាគាររបស់ក្រុមហ៊ុនតាមវិធីផ្សេងៗដែលមាន។

បុព្វលាភធានារ៉ាប់រង និងរបៀបនៃការបង់បុព្វលាភធានារ៉ាប់រង ត្រូវបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិត ឬលិខិតបញ្ជាក់ការផ្លាស់ប្តូរចុងក្រោយបំផុត ប្រសិនបើមាន។ ម្ចាស់បណ្ណសន្យារ៉ាប់រង ជាអ្នកទទួលខុសត្រូវលើការបង់ពន្ធណាមួយដែលអនុវត្តចំពោះបណ្ណសន្យារ៉ាប់រងដែលបានចេញជូន ប្រសិនបើមាន។

៦. ករណីមិនធានា

៦.១ អត្ថប្រយោជន៍ករណីមរណភាព ឬករណីពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដោយសារករណីគ្រោះថ្នាក់ចៃដន្យ ឬមិនបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ៖

ក្រុមហ៊ុនរក្សាសិទ្ធិក្នុងការបដិសេធចំពោះអ្នកទទួលផលម្នាក់ ឬច្រើននាក់ លើការទាមទារសំណងលើការទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ប្រសិនបើមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍របស់អ្នកត្រូវបានធានារ៉ាប់រង បណ្តាលមកពីមូលហេតុណាមួយ ដោយផ្ទាល់ ឬដោយប្រយោលដូចខាងក្រោម៖

(i) ការធ្វើអត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាត ឬធ្វើឲ្យរបួសខ្លួនឯង ទោះបីជាស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ ក្នុងរយៈពេលពីរឆ្នាំ គិតចាប់ពីកាលបរិច្ឆេទមានសុពលភាពនៃបណ្ណសន្យារ៉ាប់រង ឬដោយគិតចាប់ពីកាលបរិច្ឆេទមានសុពលភាពនៃការបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ដោយយកកាលបរិច្ឆេទចុងក្រោយគេ ឬ

(ii) មេរោគអេដស៍ និង/ឬជំងឺណាមួយដែលជាប់ទាក់ទងនឹងមេរោគអេដស៍រួមទាំងជំងឺអេដស៍ និង/ឬការផ្លាស់ប្តូរ ការវិវត្តន៍ ឬការប្រែប្រួលនៃមេរោគអេដស៍ និង/ឬជំងឺដែលជាប់ទាក់ទងនឹងមេរោគអេដស៍រួមទាំងជំងឺអេដស៍ ឬ

(iii) ការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ ដោយម្ចាស់បណ្ណសន្យារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផលមួយ ឬច្រើន ឬ

(iv) ការប្រើគ្រឿងញៀន ឬថ្នាំសប្បាយ ការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ដូចមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ក្នុងករណីនេះ ប្រសិនបើក្រុមហ៊ុនធ្វើការបដិសេធចំពោះសំណើទាមទារសំណងស្របតាមប្រការ ៦.១ ក្រុមហ៊ុននឹងធ្វើការទូទាត់ឱ្យវិញនូវចំនួនទឹកប្រាក់ ដូចខាងក្រោម៖

(i) បុព្វលាភធានារ៉ាប់រង ដោយដកយកមកវិញនូវ

(ii) ថ្លៃពិនិត្យសុខភាពណាមួយដែលបានចំណាយ ប្រសិនបើមាន ដោយដកយកមកវិញនូវ

(iii) ចំនួនទឹកប្រាក់ណាមួយដែលនៅជំពាក់ក្រុមហ៊ុន ប្រសិនបើមាន។

បណ្ណសន្យារ៉ាប់រងនឹងត្រូវបញ្ចប់ បន្ទាប់ពីការទូទាត់អត្ថប្រយោជន៍នេះ។

៦.២ អត្ថប្រយោជន៍ករណីមរណភាព ឬ ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដោយសារគ្រោះថ្នាក់ចៃដន្យ៖

អ្នកដែលត្រូវបានធានារ៉ាប់រងមិនទទួលបានអត្ថប្រយោជន៍នេះទេ ក្នុងករណីអ្នកដែលត្រូវបានធានារ៉ាប់រងទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដែលបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ ប្រសិនបើមានហេតុការណ៍ណាមួយក្នុងករណីមិនធានាក្នុងប្រការ ៦.១ កើតឡើង។

លើសពីនេះទៅទៀត ក្រុមហ៊ុនរក្សាសិទ្ធិក្នុងការបដិសេធការទាមទារសំណងចំពោះការទទួលមរណភាព ឬ ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ដោយសារគ្រោះថ្នាក់ចៃដន្យ ប្រសិនបើមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍របស់អ្នកត្រូវបានធានារ៉ាប់រងនោះ បណ្តាលមកពីមូលហេតុណាមួយដូចបានរៀបរាប់ខាងក្រោម ទោះដោយផ្ទាល់ ឬប្រយោលក្តី៖

(i) ការចូលរួមនៅក្នុងសកម្មភាពកីឡាដែលងាយមានគ្រោះថ្នាក់ មានដូចជា ការមុជក្រោមទឹកដែលចាំបាច់ត្រូវប្រើបំពង់អុកស៊ីសែន ការឡើងភ្នំ ការលោតឆ័ត្រយោង ឬការប្រណាំងយកល្បឿនលឿន ឬសកម្មភាពកីឡាអាជីពផ្សេងៗ ឬសកម្មភាពអាជីពនានាដែលពាក់ព័ន្ធនឹងការបោសសំអាតគ្រឿងមិនទាន់ផ្ទុះ ឬ

(ii) ការចូលរួមក្នុងសកម្មភាពអាកាសចរណ៍នានា លើកលែងតែជាអ្នកដំណើរដែលត្រូវបង់ប្រាក់ថ្លៃធ្វើដំណើរ តាមយន្តហោះពហុម៉ាស៊ីន យន្តហោះមានកាលវិភាគធ្វើដំណើរត្រឹមត្រូវ និងយន្តហោះមានអាជ្ញាបណ្ណធ្វើពាណិជ្ជកម្មត្រឹមត្រូវ ឬ

(iii) សកម្មភាពសង្គ្រាម ឬអំពើហិង្សា រួមមានដូចជា ការឈ្លានពាន សកម្មភាពបង្កហេតុដោយប្រទេសបរទេសណាមួយ សកម្មភាពបង្កហេតុដោយសត្រូវណាម្នាក់ (ទោះបីជាមាន ឬគ្មានការប្រកាសសង្គ្រាមក៏ដោយ) សង្គ្រាមស៊ីវិល ការចូលរួម យ៉ាងសកម្មក្នុងសកម្មភាពភេរវកម្ម អំពើបះបោរ បដិវត្តន៍ កុប្បកម្ម ការជ្រៀតជ្រែករបស់អាជ្ញាធរយោធា ឬការដណ្តើមអំណាច ឬ

(iv) រាល់ជំងឺដែលបណ្តាលមកពីការខាំ ឬទិច ដោយសត្វល្អិត រួមទាំងមូសខាំ និងដង្កូវ ឬសត្វល្អិតរាតត្បាតក្នុងរាង—កាយ។

ក្នុងករណីនេះ ប្រសិនបើក្រុមហ៊ុនធ្វើការបដិសេធចំពោះសំណើទាមទារសំណង ដោយយោងតាមប្រការ ៦.២ នេះ ប៉ុន្តែការទាមទារសំណងនោះបែរជាអាចទទួលយកបាន ស្របតាមប្រការ ៦.១ ទៅវិញ នោះក្រុមហ៊ុននឹងធ្វើការទូទាត់ឱ្យវិញនូវចំនួនទឹកប្រាក់ ដូចខាងក្រោម៖

(i) អត្ថប្រយោជន៍ករណីមរណភាព ឬករណីពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ដែលមិនបណ្តាលមកពីគ្រោះថ្នាក់ចៃដន្យ ដូចមានចែងនៅក្រោមប្រការ ៤.១ និងប្រការ ៤.៣ ឬនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិត ឬលិខិតបញ្ជាក់ពីការផ្លាស់ប្តូរចុងក្រោយបំផុត ប្រសិនបើមាន ដោយដកយកមកវិញនូវ

(ii) ចំនួនទឹកប្រាក់ណាមួយដែលនៅជំពាក់ក្រុមហ៊ុន ប្រសិនបើមាន។

ក្នុងករណីដែលក្រុមហ៊ុនធ្វើការបដិសេធចំពោះសំណើទាមទារសំណង ដោយយោងតាមប្រការ ៦.១ និង ៦.២ ខាងលើ នោះក្រុមហ៊ុននឹងធ្វើការទូទាត់ឱ្យវិញនូវចំនួនទឹកប្រាក់ ដូចខាងក្រោម៖

(i) បុព្វលាភធានារ៉ាប់រង ដោយដកយកមកវិញនូវ

(ii) ថ្លៃពិនិត្យសុខភាពណាមួយដែលបានចំណាយ បើសិនបើមាន ដោយដកយកមកវិញនូវ

(iii) ចំនួនទឹកប្រាក់ណាមួយដែលនៅជំពាក់ក្រុមហ៊ុន ប្រសិនបើមាន។

បណ្ណាសន្យារ៉ាប់រងនឹងត្រូវបញ្ចប់ បន្ទាប់ពីការទូទាត់អត្ថប្រយោជន៍នេះ។

៧. ទីតាំងភូមិសាស្ត្រនៃការធានា

វិសាលភាពនៃការការពារដែលស្ថិតនៅក្រោមផលិតផលធានារ៉ាប់រងនេះ គឺទូទាំងពិភពលោក។

ព្រះរាជាណាចក្រកម្ពុជា
ប្រមុំនៃប្រជាជាតិ
(ខេមបូឌា) ផ្តាយស៍ អ៊ិនស៊ួរែនស៍ ប.អ
PRUDENTIAL (CAMBODIA) LIFE ASSURANCE PLC
KINGDOM OF CAMBODIA

៨. លក្ខណៈសម្បត្តិអ្នកទទួលផល ឬអ្នកទទួលសំណង

ក. អ្នកទទួលផលត្រូវតែកំណត់ក្រោមបណ្ណសន្យារ៉ាប់រង ហើយអ្នកទទួលផលនឹងត្រូវទូទាត់ជូននូវអត្ថប្រយោជន៍របស់បណ្ណសន្យារ៉ាប់រងនេះ ប្រសិនបើ និងនៅពេលបណ្ណសន្យារ៉ាប់រងនេះបានស្នើសុំទាមទារសំណងដែលមានសុពលភាព ទៅលើករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ នៃអ្នកត្រូវបានធានារ៉ាប់រង។

ខ. អ្នកទទួលផលបានកំណត់ជាស្វ័យប្រវត្តិ ប៉ុន្តែម្ចាស់បណ្ណសន្យារ៉ាប់រងក៏មានសិទ្ធិក្នុងការកែប្រែ អ្នកទទួលផលម្នាក់ ឬច្រើននាក់ភ្លាមៗ ក្រោយពេលបណ្ណសន្យារ៉ាប់រងបានចេញដោយក្រុមហ៊ុន។ ប្រសិនបើមិនមានអ្នកទទួលផលដែលផ្លាស់ប្តូរ ឬតែងតាំងសារជាថ្មីដោយម្ចាស់បណ្ណសន្យារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រងនោះទេ នោះការទូទាត់ប្រាក់អត្ថប្រយោជន៍ធានារ៉ាប់រង នឹងត្រូវផ្តល់ជូនអ្នកទទួលផលដែលបានកំណត់ដោយស្វ័យប្រវត្តិ យោងតាមលំដាប់សន្តតិជនដូចមានកំណត់ខាងក្រោម៖

- សន្តតិជនអចិន្ត្រៃយ៍ជាប្តីប្រពន្ធស្របច្បាប់
- លំដាប់ទី១ កូន(ៗ) ស្មើៗគ្នា
- លំដាប់ទី២ ឪពុកម្តាយ ស្មើៗគ្នា
- លំដាប់ទី៣ បងប្អូនបង្កើត ស្មើៗគ្នា ឬបុគ្គលផ្សេងទៀតដែលកំណត់ដោយតុលាការ។

គ. ម្ចាស់បណ្ណសន្យារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រងអាចផ្លាស់ប្តូរអ្នកទទួលផល ក្នុងអំឡុងពេលបណ្ណសន្យារ៉ាប់រងនៅមានសុពលភាព។

ឃ. ម្ចាស់បណ្ណសន្យារ៉ាប់រង អ្នកត្រូវបានធានារ៉ាប់រងត្រូវតែមានទំនួលខុសត្រូវក្នុងការបញ្ជាក់ពីទំនាក់ទំនងស្របច្បាប់រវាងអ្នកទទួលផល និងអ្នកត្រូវបានធានារ៉ាប់រង និង/ឬ រវាងម្ចាស់បណ្ណសន្យារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រង។

៩. ការកែប្រែកិច្ចសន្យាធានារ៉ាប់រង

៩.១ រយៈពេលសាកល្បង

ប្រសិនបើអ្នកធ្វើការសម្រេចចិត្តថាមិនបន្តជាមួយនឹងបណ្ណសន្យារ៉ាប់រងនេះទៀតទេនោះ អ្នកអាចធ្វើការលុបចោលបណ្ណសន្យារ៉ាប់រងនេះវិញ ក្នុងរយៈពេលម្ភៃមួយ (២១) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការចេញវិញ្ញាបនបត្រធានារ៉ាប់រងអាយុជីវិត។ រយៈពេលនេះហៅថា រយៈពេលសាកល្បង ឬជារយៈពេលពិចារណា។ ក្នុងករណីនេះ ក្រុមហ៊ុននឹងធ្វើការបង្វិលប្រាក់ជូនម្ចាស់បណ្ណសន្យារ៉ាប់រងវិញ ដូចខាងក្រោម៖

(i) បុព្វលាភធានារ៉ាប់រងទាំងអស់ ដែលក្រុមហ៊ុនបានទទួល ដកមកវិញនូវ

(ii) ថ្លៃពិនិត្យសុខភាពណាមួយដែលបានចំណាយ ប្រសិនបើមាន ដកមកវិញនូវ

(iii) បំណុលដែលមិនទាន់បានទូទាត់ផ្សេងទៀត ប្រសិនបើមាន ។

បន្ទាប់ពីការបង្វិលបុព្វលាភធានារ៉ាប់រងជូនរួច បណ្ណសន្យារ៉ាប់រងនេះនឹងអស់សុពលភាពភ្លាម ដោយគិតចាប់ពីកាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រង។

៩.២ ការផ្លាស់ប្តូរម្ចាស់បណ្ណសន្យារ៉ាប់រង

ការផ្លាស់ប្តូរម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវបានអនុញ្ញាត នៅពេលដែលម្ចាស់បណ្ណសន្យារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រងជាបុគ្គលផ្សេងគ្នា ដោយស្របតាមលក្ខខណ្ឌដូចខាងក្រោម៖

(i) ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងមានអាយុគ្រប់ដប់ប្រាំបី (១៨) ឆ្នាំ ហើយអ្នកត្រូវបានធានារ៉ាប់រងនោះអាចក្លាយជាម្ចាស់បណ្ណសន្យារ៉ាប់រងថ្មី ឬម្ចាស់បណ្ណសន្យារ៉ាប់រងបច្ចុប្បន្ន និងអ្នកត្រូវបានធានារ៉ាប់រង អាចចាត់តាំងបុគ្គលផ្សេងទៀតដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ជាម្ចាស់បណ្ណសន្យារ៉ាប់រងថ្មី ឬ

(ii) ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រងបច្ចុប្បន្នទទួលមរណភាព ខណៈដែលបណ្ណសន្យារ៉ាប់រងនៅមានសុពលភាព ហើយអ្នកត្រូវបានធានារ៉ាប់រង មានអាយុគ្រប់ដប់ប្រាំបី (១៨) ឆ្នាំ នោះអ្នកត្រូវបានធានារ៉ាប់រង អាចក្លាយជាម្ចាស់បណ្ណសន្យារ៉ាប់រងថ្មី ឬអាចចាត់តាំងបុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាម្ចាស់បណ្ណសន្យារ៉ាប់រងថ្មី ឬ

(iii) ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រងបច្ចុប្បន្នទទួលមរណភាព ខណៈដែលបណ្ណសន្យារ៉ាប់រងនៅមានសុពលភាព ហើយអ្នកត្រូវបានធានារ៉ាប់រងមានអាយុក្រោមដប់ប្រាំបី (១៨) ឆ្នាំ នោះសាច់ញាតិជិតស្និទ្ធរបស់អ្នកត្រូវបានធានារ៉ាប់រងនឹងអាចចាត់តាំងជាម្ចាស់បណ្ណសន្យារ៉ាប់រងថ្មី ដោយមានការយល់ព្រមពីអាណាព្យាបាលស្របច្បាប់របស់អ្នកត្រូវបានធានារ៉ាប់រង និងស្ថិតក្រោមការអនុម័តរបស់ក្រុមហ៊ុន ព្រមទាំងអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ម្ចាស់បណ្ណសន្យារ៉ាប់រងថ្មី ត្រូវបន្តបង់បុព្វលាភធានារ៉ាប់រង (ប្រសិនបើមាន) ដើម្បីរក្សាបណ្ណសន្យារ៉ាប់រង អោយនៅមានសុពលភាព។

ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រងបច្ចុប្បន្នទទួលមរណភាព ខណៈដែលបណ្ណសន្យារ៉ាប់រងនៅមានសុពលភាព ហើយមិនអាចចាត់តាំងម្ចាស់បណ្ណសន្យារ៉ាប់រងថ្មីដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់បានទេ បណ្ណសន្យារ៉ាប់រងនេះនឹងត្រូវបញ្ចប់ ហើយតម្លៃនៃការបោះបង់កិច្ចសន្យារ៉ាប់រងនឹងត្រូវបានផ្តល់ជូន ដូចបានចែងក្នុងចំណុច ១១។

៩.៣ ម្ចាស់បណ្ណសន្យារ៉ាប់រង ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ក្រុមហ៊ុន អំពីការផ្លាស់ប្តូរណាមួយនៃអាសយដ្ឋានទីលំនៅបច្ចុប្បន្នរបស់ខ្លួន។ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងឈប់រស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនអាចនឹងបន្តបណ្ណសន្យារ៉ាប់រងនេះជាមួយ នឹងបុព្វលាភធានារ៉ាប់រងសរុបដដែល ឬតម្លើងបុព្វលាភធានារ៉ាប់រងសរុប ដើម្បីបន្តបណ្ណសន្យារ៉ាប់រង ឬបញ្ចប់បណ្ណសន្យារ៉ាប់រង ស្របតាមបទប្បញ្ញត្តិស្តីពីការចេញបណ្ណសន្យារ៉ាប់រងរបស់ក្រុមហ៊ុនដែលមានជាធរមាន។

៩.៤ ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រងប្តូរអត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែន ឬឯកសារសម្គាល់អត្តសញ្ញាណណាមួយផ្សេងទៀតដែលបានប្រើសម្រាប់ការទិញបណ្ណសន្យារ៉ាប់រងនេះ នោះម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវតែជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ក្រុមហ៊ុន ដោយបញ្ជាក់អំពីការផ្លាស់ប្តូរទាំងអស់នៃឯកសារសម្គាល់អត្តសញ្ញាណទាំងនោះ។ លក្ខខណ្ឌដែលបានកែប្រែនឹងចូលជាធរមានបន្ទាប់ពីក្រុមហ៊ុន បានផ្តល់ការឯកភាពជាលាយលក្ខណ៍អក្សររបស់ខ្លួនចំពោះការកែប្រែនោះ ហើយឯកសារនោះនឹងក្លាយជាឯកសារផ្លូវការ និងស្របច្បាប់មួយនៃបណ្ណសន្យារ៉ាប់រងនេះ។

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន ប្រ៊ូដិនសេ
(ខេមបូឌា) ផ្ទាយស៊ី អ៊ិនស៊ួរែនស៍ ប.អ
PRUDENTIAL (CAMBODIA) LIFE ASSURANCE PLC
KINGDOM OF CAMBODIA

៩.៥ ការផ្លាស់ប្តូរការងាររបស់អ្នកត្រូវបានធានារ៉ាប់រង

ក្នុងករណីដែលមានការផ្លាស់ប្តូរការងាររបស់អ្នកត្រូវបានធានារ៉ាប់រង ឬអ្នកត្រូវបានធានារ៉ាប់រង ចូលរួមនៅក្នុងសកម្មភាពកីឡាគ្រោះថ្នាក់ណាមួយ (ដូចជា ការមុជក្រោមទឹក ការឡើងភ្នំ ការលោតឆ័ត្រយោង ប្រណាំងម៉ូតូ/រថយន្ត -ល-) ម្ចាស់បណ្ណសន្យារ៉ាប់រង ត្រូវតែជូនដំណឹងដល់ក្រុមហ៊ុនក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ បន្ទាប់ពីការកើតមានឡើងនូវការផ្លាស់ប្តូរនោះ បើមិនដូច្នោះទេ ក្រុមហ៊ុនអាចនឹងបដិសេធមិនធ្វើការទូទាត់ប្រាក់សំណងឡើយ ប្រសិនបើមានព្រឹត្តិការណ៍ឋិតក្នុងការធានាកើតឡើង។ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលក្រុមហ៊ុនទទួលបានឯកសារពេញលេញអំពីការផ្លាស់ប្តូរការងាររបស់អ្នកត្រូវបានធានារ៉ាប់រង ឬការជូនដំណឹងអំពីការចូលរួមនៅក្នុងសកម្មភាពកីឡាដែលមានគ្រោះថ្នាក់របស់អ្នកត្រូវបានធានារ៉ាប់រង ក្រុមហ៊ុននឹងធ្វើការសម្រេចចិត្តថាតើនឹងបន្តទទួលធានារ៉ាប់រងនៅកម្រិតបុព្វលាភធានារ៉ាប់រងដដែល ឬផ្លាស់ប្តូរកម្រិតបុព្វលាភធានារ៉ាប់រងនោះ ឬបន្ថែមករណីមិនទទួលធានាពិសេសណាមួយ។

៩.៦ ម្ចាស់បណ្ណសន្យារ៉ាប់រងមានសិទ្ធិធ្វើការកែប្រែផ្សេងទៀត ដូចខាងក្រោម៖

(i) ផ្លាស់ប្តូររបៀបបង់បុព្វលាភធានារ៉ាប់រងសរុប ក្នុងរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង។

(ii) លុបចោលគម្រោងលក្ខខណ្ឌបន្ថែមណាមួយ ក្នុងរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង ប្រសិនបើមាន។

ម្ចាស់បណ្ណសន្យារ៉ាប់រង ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ក្រុមហ៊ុន ដោយបញ្ជាក់អំពីការស្នើសុំផ្លាស់ប្តូរនោះ។ លក្ខខណ្ឌដែលត្រូវបានកែប្រែនោះ នឹងត្រូវចូលជាធរមាន បន្ទាប់ពីក្រុមហ៊ុនបានចេញលិខិតឯកភាពជាលាយលក្ខណ៍អក្សររបស់ខ្លួនចំពោះការកែប្រែនោះ ហើយឯកសារនោះនឹងក្លាយជាឯកសារផ្លូវការ និងស្របច្បាប់មួយនៃបណ្ណសន្យារ៉ាប់រង។

១០. ការអស់សុពលភាពជាបណ្តោះអាសន្ន ឬការផ្អាកកិច្ចសន្យាធានារ៉ាប់រង ឬការបន្តសុពលភាព ឬការបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ

១០.១ ការអស់សុពលភាពជាបណ្តោះអាសន្ន ឬការផ្អាកកិច្ចសន្យាធានារ៉ាប់រង

វាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ម្ចាស់បណ្ណសន្យារ៉ាប់រង ក្នុងការបន្តបង់បុព្វលាភធានារ៉ាប់រងឱ្យបានទៀងទាត់ និងទាន់ពេលវេលា ដើម្បីបន្តអត្ថប្រយោជន៍ធានារ៉ាប់រងដែលនឹងត្រូវទទួលបានក្រោមបណ្ណសន្យារ៉ាប់រង។ បណ្ណសន្យារ៉ាប់រងនឹងក្លាយជាបណ្ណសន្យារ៉ាប់រងដែលអស់សុពលភាពជាបណ្តោះអាសន្ន ប្រសិនបើអ្នកខកខានក្នុងការបង់បុព្វលាភធានារ៉ាប់រងសរុប រហូតដល់ថ្ងៃផុតកំណត់នៃរយៈពេលអនុគ្រោះ។ កាលបរិច្ឆេទអស់សុពលភាពជាបណ្តោះអាសន្ននេះ គឺជាកាលបរិច្ឆេទដល់កំណត់បង់បុព្វលាភធានារ៉ាប់រង នៃបុព្វលាភធានារ៉ាប់រងដែលពុំទាន់បានបង់ដំបូងគេបង្អស់។

១០.២ ការបន្តសុពលភាព

ម្ចាស់បណ្ណសន្យារ៉ាប់រងមានសិទ្ធិបន្តបណ្ណសន្យារ៉ាប់រងឡើងវិញ ស្របតាមកិច្ចព្រមព្រៀង។ ការបន្តបណ្ណសន្យារ៉ាប់រងឡើងវិញ ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

(i) ការបន្តសុពលភាពនៃបណ្ណសន្យារ៉ាប់រង

(ii) ការបន្តសុពលភាពបណ្ណសន្យារ៉ាប់រងដែលអស់សុពលភាពជាបណ្តោះអាសន្នឡើងវិញ។

១០.៣ ការបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ

បន្ទាប់ពីបណ្ណសន្យារ៉ាប់រងអស់សុពលភាពជាបណ្តោះអាសន្ន អត្ថប្រយោជន៍ធានារ៉ាប់រងទាំងអស់នឹងត្រូវបញ្ចប់ ហើយបណ្ណសន្យារ៉ាប់រងនោះនឹងក្លាយជាបណ្ណសន្យារ៉ាប់រងដែលអស់សុពលភាពជាបណ្តោះអាសន្ន។ នៅពេលដែលបណ្ណសន្យារ៉ាប់រងអស់សុពលភាពជាបណ្តោះអាសន្ន ម្ចាស់បណ្ណសន្យារ៉ាប់រងមានជម្រើសដូចខាងក្រោម៖

(i) ស្នើសុំបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ក្នុងរយៈពេលម្ភៃបួន (២៤) ខែ ដោយគិតចាប់ពីថ្ងៃបណ្ណសន្យារ៉ាប់រងនោះអស់សុពលភាពជាបណ្តោះអាសន្ន ឬនៅត្រឹមថ្ងៃផុតកំណត់នៃបណ្ណសន្យារ៉ាប់រង ដោយយកកាលបរិច្ឆេទមុនគេ ដោយគ្រាន់តែបង់បុព្វលាភធានារ៉ាប់រងដែលនៅពុំទាន់បានបង់ទាំងអស់ និងការប្រាក់ ប្រសិនបើមាន។

(ii) បោះបង់បណ្ណសន្យារ៉ាប់រង ហើយទទួលយកតម្លៃនៃការបោះបង់កិច្ចសន្យារ៉ាប់រងដែលអាចទទួលបានគិតត្រឹមកាលបរិច្ឆេទដែលបណ្ណសន្យារ៉ាប់រងអស់សុពលភាពជាបណ្តោះអាសន្ន។

ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រង មិនបានស្នើសុំបន្តសុពលភាពបណ្ណសន្យារ៉ាប់រង ក្នុងរយៈពេល ម្ភៃបួន (២៤) ខែ ដោយគិតចាប់ថ្ងៃដែលបណ្ណសន្យារ៉ាប់រងនោះអស់សុពលភាពជាបណ្តោះអាសន្ន ឬត្រឹមថ្ងៃផុតកំណត់នៃបណ្ណសន្យារ៉ាប់រង ដោយយកកាលបរិច្ឆេទមុនគេទេនោះ ក្រុមហ៊ុននឹងបញ្ចប់បណ្ណសន្យារ៉ាប់រង។

១១. ការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង

នេះជាបណ្ណសន្យារ៉ាប់រងរយៈពេលវែង នោះវាជាឧត្តមប្រយោជន៍របស់ម្ចាស់បណ្ណសន្យារ៉ាប់រង ក្នុងការបន្តសុពលភាពបណ្ណសន្យារ៉ាប់រងនេះឲ្យបានពេញលេញគ្រប់រយៈពេលនៃបណ្ណសន្យារ៉ាប់រង ដើម្បីអាចទទួលបានអត្ថប្រយោជន៍ដ៏ប្រសើរពីបណ្ណសន្យារ៉ាប់រងនេះ។

ទោះបីជាយ៉ាងណា អ្នកមានសិទ្ធិធ្វើការស្នើសុំបោះបង់បណ្ណសន្យារ៉ាប់រងគ្រប់ពេល នៅក្នុងរយៈពេលកំណត់នៃបណ្ណសន្យារ៉ាប់រង។ អ្នកអាចធ្វើការស្នើសុំបោះបង់បណ្ណសន្យារ៉ាប់រង ដោយបំពេញទម្រង់បែបបទស្នើសុំបោះបង់បណ្ណសន្យារ៉ាប់រងដែលផ្តល់ដោយក្រុមហ៊ុន។ កាលបរិច្ឆេទមានសុពលភាពនៃសំណើសុំបោះបង់បណ្ណសន្យារ៉ាប់រងនេះ គឺជាកាលបរិច្ឆេទដែលក្រុមហ៊ុនទទួលបានសំណើសុំបោះបង់បណ្ណសន្យារ៉ាប់រងដែលបានចុះហត្ថលេខាត្រឹមត្រូវ និងបំពេញបានពេញលេញពីម្ចាស់បណ្ណសន្យារ៉ាប់រង។

នៅពេលទទួលបានទម្រង់បែបបទស្នើសុំបោះបង់របស់អ្នក ក្រុមហ៊ុនត្រូវទូទាត់តម្លៃនៃការបោះបង់កិច្ចសន្យាធានារ៉ាប់រងជូនម្ចាស់បណ្ណសន្យារ៉ាប់រង។ បន្ទាប់ពីក្រុមហ៊ុនទូទាត់តម្លៃនៃការបោះបង់កិច្ចសន្យារ៉ាប់រងនេះរួច បណ្ណសន្យារ៉ាប់រងនេះនឹងអស់សុពលភាព ហើយអត្ថប្រយោជន៍ពាក់ព័ន្ធនឹងបណ្ណសន្យារ៉ាប់រងនេះទាំងអស់នឹងត្រូវបញ្ចប់ផងដែរ។

១២. ការលុបចោលកិច្ចសន្យាធានារ៉ាប់រង

បណ្ណសន្យារ៉ាប់រងនេះ នឹងត្រូវបញ្ចប់ដោយស្វ័យប្រវត្តិនៅពេលដែលមានហេតុការណ៍ណាមួយដូចខាងក្រោមកើតឡើង៖

(i) ម្ចាស់បណ្ណសន្យារ៉ាប់រងបំពាននូវប្រការមួយ ឬច្រើននៃបណ្ណសន្យារ៉ាប់រងនេះ ឬ

(ii) អ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ឬ

(iii) រយៈពេលកំណត់នៃផលិតផលធានារ៉ាប់រងផុតកំណត់ ឬ

(iv) អ្នកត្រូវបានធានារ៉ាប់រងបានឈានដល់អាយុផុតកំណត់ ឬ

(v) ម្ចាស់បណ្ណសន្យារ៉ាប់រងស្នើសុំលុបចោលបណ្ណសន្យារ៉ាប់រងនេះ ឬ

(vi) បណ្ណសន្យារ៉ាប់រងត្រូវបានបោះបង់ដោយយោងតាមចំណុច ១១ ឬ

(vii) ក្រុមហ៊ុនព្រ្ជិនសលបានទូទាត់អត្ថប្រយោជន៍ពេញលេញក្រោមបណ្ណសន្យារ៉ាប់រងនេះ ឬ

(viii) ក្រុមហ៊ុនរក្សាសិទ្ធិក្នុងការលុបចោលបណ្ណសន្យារ៉ាប់រង ឬបដិសេធលើសំណើសុំទាមទារសំណងករណីម្ចាស់បណ្ណសន្យារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រង ក្រោមបណ្ណសន្យារ៉ាប់រងនេះ ផ្តល់ព័ត៌មានមិនពិត ឬមិនត្រឹមត្រូវ ដែលមានសារៈសំខាន់សម្រាប់ធ្វើការវាយតម្លៃអំពីហានិភ័យ ដើម្បីចេញបណ្ណសន្យារ៉ាប់រង និងការធានារ៉ាប់រងនៃបណ្ណសន្យារ៉ាប់រងនេះ ឬ

(ix) លក្ខខណ្ឌផ្សេងទៀត ដែលត្រូវបានកំណត់នៅក្នុងច្បាប់និងបទបញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា។

នៅពេលបណ្ណសន្យារ៉ាប់រងបានបញ្ចប់ មិនមានអត្ថប្រយោជន៍ណាមួយត្រូវបានទូទាត់ក្រោមបណ្ណសន្យានេះទេ។

១៣. និតិវិធីនៃការទាមទារសំណង

ក្រុមហ៊ុនមានកាតព្វកិច្ចទូទាត់ប្រាក់អត្ថប្រយោជន៍ក្រោមបណ្ណសន្យារ៉ាប់រងនេះ ទៅឲ្យអ្នកទទួលផល ឬអ្នកទទួលសំណង ស្របតាមឯកសារនៃបណ្ណសន្យារ៉ាប់រងនេះ លុះត្រាណាតែក្រុមហ៊ុនទទួលបានភស្តុតាងដែលចាំបាច់ និងអាចទុកចិត្តបានសម្រាប់ការដោះស្រាយសំណង។

ឯកសារខាងក្រោមនេះ ចាំបាច់ត្រូវមានសម្រាប់ការវាយតម្លៃទៅលើការទាមទារសំណង៖

(i) ទម្រង់បែបបទមួយដែលបានបំពេញចប់សព្វគ្រប់ ស្របតាមបទដ្ឋានរបស់ក្រុមហ៊ុនស្តីពីការស្នើសុំការទូទាត់ប្រាក់អត្ថប្រយោជន៍ធានារ៉ាប់រង និង

(ii) ភស្តុតាងផ្សេងៗដែលចាំបាច់ដើម្បីបញ្ជាក់អំពីសិទ្ធិរបស់អ្នកទាមទារសំណង ក្នុងការទទួលបានអត្ថប្រយោជន៍ (ដូចជាភស្តុតាង ដែលបញ្ជាក់ពីទំនាក់ទំនងរវាងអ្នកទទួលផល និងអ្នកត្រូវបានធានារ៉ាប់រង) និង

(iii) រាល់ឯកសារពាក់ព័ន្ធទាំងអស់ ដូចជា៖

ក. សំបុត្រមរណភាព លិខិតបញ្ជាក់ពីពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ ភស្តុតាងបញ្ជាក់ពីគ្រោះថ្នាក់ និងលិខិតបញ្ជាក់ផ្សេងទៀតដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច ដោយចំណាយទាំងនេះជាបន្ទុករបស់អ្នកទាមទារសំណង។

ព្រះរាជាណាចក្រកម្ពុជា
(ទេមបុជ) ស្ថាយប្រ៊ូដិនសែ ម.ភ
PRUDENTIAL (CAMBODIA) LIFE ASSURANCE PLC
KINGDOM OF CAMBODIA

ខ. ឯកសារថតចម្លងនៃការបញ្ជាក់ពីវេជ្ជបណ្ឌិត ឬវិញ្ញាបនបត្រវេជ្ជសាស្ត្រ ចេញដោយគ្លេពេទ្យជំនាញទៅលើករណីត្រូវបានធានារ៉ាប់រង (ឯកសារត្រូវជាភាសាខ្មែរ ឬភាសាអង់គ្លេស)។

(iv) អង្គហេតុ និង/ឬឯកសារណាមួយផ្សេងទៀត ដែលក្រុមហ៊ុនយល់ថាមានសារៈសំខាន់ចំពោះការវាយតម្លៃលើការទាមទារសំណងដោយចំណាយជាបន្ទុករបស់អ្នកទាមទារសំណង។

ក្នុងករណីមានការទាមទារសំណង អ្នកទាមទារសំណងអាចជូនដំណឹងអំពីការទាមទារសំណងទៅភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គល ឬបុគ្គលិកលក់រៀងៗខ្លួន ឬទាក់ទងក្រុមទាមទារសំណងរបស់ក្រុមហ៊ុន តាមរយៈព័ត៌មានទំនាក់ទំនងដូចដែលមានចែងក្នុងគេហទំព័ររបស់ក្រុមហ៊ុន។ រយៈពេលកំណត់សម្រាប់ការទាមទារអត្ថប្រយោជន៍ ក្រោមបណ្ណាសន្យារ៉ាប់រងនេះត្រូវមានអំឡុងពេលដូចខាងក្រោម៖

(i) បណ្ណាសន្យារ៉ាប់រងមិនអាចធ្វើការទាមទារសំណងបានទេ លុះត្រាតែស្នើសុំក្នុងអំឡុងពេល ម្ភៃបួន (២៤) ខែ បន្ទាប់ពីថ្ងៃដែលអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព

(ii) ដប់ពីរ (១២) ខែ គិតចាប់ពីពេលចេញការវាយតម្លៃ ដោយមន្ត្រីសុខាភិបាលស្តីពីពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍របស់អ្នកត្រូវបានធានារ៉ាប់រង។

ក្រុមហ៊ុនទទួលខុសត្រូវក្នុងការវាយតម្លៃលើការទាមទារសំណងក្នុងរយៈពេលដប់ប្រាំ (១៥) ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីកាលបរិច្ឆេទដែលក្រុមហ៊ុនបានទទួលបានការស្នើសុំទាមទារសំណងពេញលេញ និងទទួលបានរាល់ឯកសារភស្តុតាងដែលចាំបាច់គ្រប់គ្រាន់ទាំងអស់។

បន្ទាប់ពីការសម្រេចចិត្តរបស់ក្រុមហ៊ុនលើការទូទាត់សំណង អត្ថប្រយោជន៍នឹងត្រូវផ្ទេរទៅគណនីធនាគាររបស់អ្នកទាមទារសំណងដោយផ្អែកលើព័ត៌មានដែលបានផ្តល់ឲ្យដោយអ្នកទាមទារសំណងក្នុងអំឡុងពេលស្នើសុំទាមទារសំណងរយៈពេលបី (៣) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីអ្នកទាមទារសំណងយល់ព្រមទៅលើចំនួនទឹកប្រាក់សំណង ឬក្នុងរយៈពេលដូចដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងទូទាត់សំណងរវាងក្រុមហ៊ុន និងអ្នកទាមទារលើការទូទាត់សំណងជាដំណាក់កាល។

ក្រុមហ៊ុន មានសិទ្ធិដំទាស់ទៅលើសុពលភាពនៃបណ្ណាសន្យារ៉ាប់រងក្នុងរយៈពេលពីរ (២) ឆ្នាំដំបូង រាប់ចាប់ពីកាលបរិច្ឆេទចេញបណ្ណាសន្យារ៉ាប់រង ឬពីកាលបរិច្ឆេទនៃការបន្តសុពលភាពបណ្ណាសន្យារ៉ាប់រងឡើងវិញ (ដោយយកកាលបរិច្ឆេទចុងក្រោយគេ)។ ក្រុមហ៊ុនអាចធ្វើការកែសម្រួលបណ្ណាសន្យារ៉ាប់រងដោយមានកិច្ចព្រមព្រៀងរវាងម្ចាស់បណ្ណាសន្យារ៉ាប់រង និងក្រុមហ៊ុន ឬបញ្ចប់កិច្ចសន្យាធានារ៉ាប់រង។

ក្នុងករណីបញ្ចប់កិច្ចសន្យាធានារ៉ាប់រងតាមលក្ខខណ្ឌនេះ ក្រុមហ៊ុនត្រូវបង់ប្រាក់ដែលមានចំនួនស្មើនឹង៖

ក. បុព្វលាភធានារ៉ាប់រងទាំងអស់ដែលក្រុមហ៊ុនបានទទួល ដោយដកមកវិញនូវ

ខ. ថ្លៃពិនិត្យសុខភាពណាមួយដែលបានចំណាយ ប្រសិនបើមាន ដោយដកមកវិញនូវ

គ. ចំនួនទឹកប្រាក់ផ្សេងៗ ដែលមិនទាន់ទូទាត់មកក្រុមហ៊ុន ប្រសិនបើមាន។

ក្រុមហ៊ុនត្រូវជូនដំណឹងដល់ម្ចាស់បណ្ណសន្យារ៉ាប់រងក្នុងរយៈពេលបី (៣) ថ្ងៃធ្វើការ ប្រសិនជាព័ត៌មានមិនពិត ត្រូវបានរកឃើញ។

លើកលែងតែការបំភាន់ដោយចេតនាទៅលើការផ្តល់ព័ត៌មាន និង/ឬការបដិសេធការទាមទារសំណងដោយយោងតាមចំណុចទី ៦ ករណីមិនធានា ក្រុមហ៊ុនមិនអាចជំទាស់ពីសុពលភាពរបស់បណ្ណសន្យារ៉ាប់រងដែលកំពុងមានសុពលភាព ក្នុងអំឡុងពេលរស់រានមានជីវិតរបស់អ្នកត្រូវបានធានារ៉ាប់រង បន្ទាប់ពីបណ្ណសន្យារ៉ាប់រងមានសុពលភាពយ៉ាងហោចណាស់ពីរ (២) ឆ្នាំ រាប់ចាប់ពីកាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រង ឬពីកាលបរិច្ឆេទនៃការបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ដោយយកកាលបរិច្ឆេទចុងក្រោយគេ។

១៤. ការរក្សាព័ត៌មានសម្ងាត់

រាល់ព័ត៌មានដែលម្ចាស់បណ្ណសន្យារ៉ាប់រង និង/ឬ អ្នកត្រូវបានធានារ៉ាប់រង បានផ្តល់ជូនក្រុមហ៊ុនត្រូវរក្សាជាការសម្ងាត់យ៉ាងតឹងរឹងហើយមិនមានព័ត៌មានផ្ទាល់ខ្លួន និង/ឬឯកសារទាក់ទងនឹងវេជ្ជសាស្ត្រណាមួយត្រូវបានបង្ហាញដល់ភាគីទីបីដោយគ្មានការយល់ព្រមជាមុនឡើយ លើកលែងតែ

(i) ការយល់ព្រមជាមុនត្រូវបានផ្តល់ទៅឱ្យក្រុមហ៊ុន ឬ

(ii) ជាតម្រូវការផ្នែកច្បាប់ ឬការអនុញ្ញាតដោយច្បាប់ ឬបទប្បញ្ញត្តិធរមាន។

១៥. ការផ្សះផ្សាវិវាទ

ចំពោះគ្រប់វិវាទដែលពាក់ព័ន្ធនឹងអាជីវកម្មធានារ៉ាប់រង ភាគីណាមួយនៃភាគីវិវាទអាចនាំយកវិវាទទៅជូននិយ័តករធានារ៉ាប់រងកម្ពុជា (ន.ធ.ក) ដើម្បីសម្រុះសម្រួលធ្វើការផ្សះផ្សាវិវាទមុននឹងប្តឹងទៅវេទិកាមជ្ឈត្តកម្ម ឬតុលាការមានសមត្ថកិច្ចលើកលែងតែរឿងព្រហ្មទណ្ឌ។

ចំពោះវិវាទដែលមិនអាចដោះស្រាយតាមរយៈការផ្សះផ្សាខាងលើ ភាគីនីមួយៗអាចដាក់វិវាទនេះទៅដោះស្រាយនៅតុលាការនៃអាសយដ្ឋានដែលទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុនតាំងនៅ។ ថ្លៃចំណាយផ្សេងៗលើតុលាការជាបន្ទុករបស់ភាគីចាញ់ក្តី។ រយៈពេលកំណត់សម្រាប់ការដាក់បណ្តឹង លើកលែងតែការទាមទារសំណង ត្រូវមានអំឡុងពេល ៥ (ប្រាំ) ឆ្នាំគិតចាប់ពីកាលបរិច្ឆេទនៃព្រឹត្តិការណ៍ ដែលនាំឲ្យកើតមានវិវាទដោយយោងទៅតាមបទប្បញ្ញត្តិពាក់ព័ន្ធក្នុងប្រទេសដែលមានជាធរមាន។

១៦. ដែនយុត្តាធិការ

ចំណុចនេះ ត្រូវបានអនុវត្តតាមលក្ខខណ្ឌ ដូចមានចែងក្នុង ខ និងលក្ខខណ្ឌនៃដែនយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជា។

១៧. ប្រការស្តីពី ទណ្ឌកម្ម

"ទណ្ឌកម្ម" មានន័យថា វិធានការរឹតត្បិតដែលបានដាក់លើរបបនយោបាយ ប្រទេស រដ្ឋាភិបាល អង្គភាព បុគ្គល និង ឧស្សាហកម្មទាំងឡាយណា ដែលបានកំណត់ដោយស្ថាប័នអន្តរជាតិ ឬរដ្ឋាភិបាលក្នុងប្រទេសកម្ពុជា ឬនៅក្រៅប្រទេសកម្ពុជាដែលរាប់បញ្ចូល ប៉ុន្តែមិនកំណត់ចំពោះតែ ការិយាល័យអនុវត្តទណ្ឌកម្មហិរញ្ញវត្ថុនៃរតនាគារជាតិចក្រភពអង់គ្លេស អង្គការសហប្រជាជាតិ សហភាពអឺរ៉ុប ការិយាល័យគ្រប់គ្រងទ្រព្យសម្បត្តិបរទេសនៃនាយកដ្ឋានរតនាគារសហរដ្ឋអាមេរិក និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ កម្ពុជា។

ទោះបីជាមានអ្វីផ្ទុយទៅនឹងបណ្ណាសន្យាវ៉ាប់រងនេះក៏ដោយ ប្រសិនបើ៖

(i) យើងដឹង ឬទទួលបានដំណឹងថាម្ចាស់បណ្ណាសន្យាវ៉ាប់រង អ្នកត្រូវបានធានាវ៉ាប់រង ឬអត្ថគាហកដទៃទៀត ដែលមានឈ្មោះក្នុងដំណាក់កាលដាក់ពាក្យស្នើសុំ អ្នកត្រូវបានចាត់តាំង (nominee) អ្នកទទួលផល បុគ្គលណាម្នាក់ ឬអង្គភាពទាំងឡាយណាដែលមានទំនាក់ទំនងជាមួយបណ្ណាសន្យាវ៉ាប់រងនេះ (រាប់បញ្ចូលទាំងអ្នកបង់ប្រាក់) មានឈ្មោះក្នុងបញ្ជីទណ្ឌកម្មណាមួយឬ

(ii) ប្រសិនបើយើង ឬធនាគារ ឬភាគីទីបីដែលពាក់ព័ន្ធត្រូវបានរកឃើញថាមានការរំលោភបំពានទៅលើកាតព្វកិច្ចនៃគោលការណ៍ដាក់ទណ្ឌកម្ម តាមរយៈការចាត់វិធានការណាមួយទៅលើបណ្ណាសន្យាវ៉ាប់រងនេះ យើងចាំបាច់បញ្ចប់បណ្ណាសន្យាវ៉ាប់រងនេះដោយមានអនុភាពភ្លាមៗ និង/ឬចាត់វិធានការផ្សេងទៀតដែលយើងគិតថាសមរម្យ រួមមានប៉ុន្តែមិនកំណត់ចំពោះតែ ការជូនដំណឹងដល់អាជ្ញាធររដ្ឋាភិបាលដែលពាក់ព័ន្ធ ការឃាត់ឃាំងការទូទាត់ប្រាក់ណាមួយ ការបង្កកប្រាក់ដែលបានទូទាត់ជូនយើងខ្ញុំ និងការផ្ទេរការទូទាត់ ឬប្រាក់ទៅកាន់អាជ្ញាធររដ្ឋាភិបាលដែលពាក់ព័ន្ធណាមួយ។

យើងនឹងមិនទទួលខុសត្រូវចំពោះរាល់ការខាតបង់ណាមួយដែលអ្នក ឬនរណាម្នាក់ផ្សេងទៀតអាចទទួលរង ដោយសារការចាត់វិធានការរបស់យើងក្រោមប្រការនេះ។

ប្រការនេះ និងលទ្ធភាពរបស់យើង ក្នុងការទាមទារសំណងសម្រាប់ការខាតបង់ណាមួយដែលយើងអាចទទួលរងដោយសារការប្រតិបត្តិ នៃប្រការនេះ នឹងមានសុពលភាពជដែល ទោះបីបណ្ណាសន្យាវ៉ាប់រងនេះត្រូវបានបញ្ចប់ក៏ដោយ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
(ទេមបុជ) ក្រុមហ៊ុន ប្រ៊ូដិនសេ ម.ភ
PRUDENTIAL (CAMBODIA) LIFE ASSURANCE PLC
KINGDOM OF CAMBODIA